# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងរដ្ឋប្បវេណី
លេខ ១២១១
ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣
រឿងក្ដី ប្ដឹងសុំទាមទារប្រាក់
សាលក្រមលេខ ០០៩ "ធ"
ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

សាលាដំបូងខេត្តកណ្ដាល បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈនៅថ្ងៃច័ន្ទ ២ រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧ ត្រូវនឹងថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៤ វេលាម៉ោង៩ព្រឹក

**ដោយមានសមាសភាពដូចតទៅ:**

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

សាលាដំបូងខេត្តកណ្ដាល បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ទៅលើសំណុំរឿងរដ្ឋប្បវេណី លេខ **១២១១** ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ ដែលមានគូភាគីដូចខាងក្រោម:

-ដើមចោទឈ្មោះ [redacted] **ស៊ុយ** ភេទប្រុស អាយុ ៤១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន [redacted]។

អ្នកតំណាងដោយអាណត្តិលោកមេធាវី [redacted]។

-ចុងចម្លើយឈ្មោះ [redacted] **ផល្លា** ភេទស្រី អាយុ ៣៦ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន [redacted]។

អ្នកតំណាងដោយអាណត្តិលោកមេធាវី [redacted]។

### ១.<u>អង្គហេតុនិងចំនុចវិវាទ:</u>

**១.១-<u>សាលក្រមដែលដើមចោទទាមទារ</u>**

ដើមចោទទាមទារឲ្យតុលាការចេញសាលក្រមដូចតទៅ:

**ក**/-ទាមទារប្រាក់ដើមទាំងពីរលើកចំនួន ៦,០០០ ដុល្លារអាមេរិក។

**ខ**/-ការប្រាក់ទាំងពីរលើកសរុបចំនួន ៧,៦៨០ ដុល្លារអាមេរិក។

**គ**/-សំណងជម្ងឺចិត្ត ៤,៥០០ ដុល្លារអាមេរិក។

**ឃ**/-សេវាកម្មច្បាប់ ៣,៥០០ ដុល្លារអាមេរិក។

**១.២-<u>សេចក្ដីពន្យល់ត្រួសៗពីអង្គហេតុ</u>**

នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៣ ឈ្មោះ [redacted] ផល្លា បានខ្ចីប្រាក់ពីឈ្មោះ [redacted] ស៊ុយ ចំនួន ៣,០០០ ដុល្លារ ដោយមានឈ្មោះ [redacted] ផល្លី ជាអ្នកធានា ក្រោយមកឈ្មោះ [redacted] ផល្លា បានខ្ចីប្រាក់បន្ថែមទៀតចំនួន



Scanned with CamScanner

៣,០០០ ដុល្លារ ដោយដាក់ប្លង់ដី និងពុំបានធ្វើកិច្ចខ្ចីប្រាក់ទេ ក្រោយមកឈ្មោះ [redacted] ផល្លា បានមកសុំដកប្លង់ដីវិញ ដោយប្រាប់ថាយកទៅដាក់ធនាគារ ដើម្បីយកប្រាក់មកសងឈ្មោះ [redacted] ស៊ុយ។ បន្ទាប់ពីយកប្លង់ទៅដាក់ធនាគារ ឈ្មោះ [redacted] ផល្លា ពុំបានយកប្រាក់មកសងឈ្មោះ [redacted] ស៊ុយ ទេ រហូតដល់ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២២ ដោយសារឈ្មោះ [redacted] ស៊ុយ ទាមទារខ្លាំងទើបឈ្មោះ [redacted] ផល្លា វេរប្រាក់តាមវីង (Wing) ចំនួន ១,០០០ ដុល្លារ ជាការប្រាក់ឱ្យឈ្មោះ [redacted] ស៊ុយ។ បន្ទាប់មកទៀតដោយសារខ្វះខាតនៅរដូវបុណ្យភ្ជុំបិណ្ឌឈ្មោះ [redacted] ស៊ុយ បានទាមទារប្រាក់ពីឈ្មោះ [redacted] ផល្លា បន្ថែមទៀត ឈ្មោះ [redacted] ផល្លា បានវេរប្រាក់ឱ្យចំនួន ១០០ ដុល្លារបន្ថែមទៀត។ រហូតមកដល់បច្ចុប្បន្នឈ្មោះ [redacted] ផល្លា ពុំទាន់សង និងបង់ការប្រាក់ឱ្យឈ្មោះ [redacted] ស៊ុយ ឡើយ។

**១.៣-<u>សេចក្តីថ្លែងការណ៍របស់គូភាគី</u>**

**១.៣.១-<u>សេចក្តីថ្លែងការណ៍របស់ដើមចោទ</u>**

*- លោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] ស៊ុយ បានធ្វើសេចក្តីថ្លែងការណ៍ថា:* ចុងចម្លើយឈ្មោះ [redacted] ផល្លា បានខ្ចីប្រាក់លើកទី១ ពីដើមចោទដែលជាកូនក្តីរបស់ខ្លួនឈ្មោះ [redacted] ស៊ុយ ចំនួន ៣,០០០$ (បីពាន់ដុល្លារអាមេរិក) ដោយបានធ្វើឡើងនៅក្នុងកិច្ចសន្យាខ្ចីដាក់បញ្ចាំ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ ២០២២ ដោយដាក់ប្លង់ដីដើម្បីធានាកាតព្វកិច្ច និងផ្តល់ឱ្យអត្រាការប្រាក់ ២៤០$ ក្នុងមួយខែ។ ហើយចុងចម្លើយបានបង់ការប្រាក់ឱ្យដើមចោទបានរយៈពេល ០៨ខែ ចាប់ពីខែកុម្ភៈ ដល់ខែកញ្ញា ឆ្នាំ២០២២។ ក្រោយមកចុងចម្លើយឈ្មោះ [redacted] ផល្លា បានខ្ចីប្រាក់ពីដើមចោទលើកទី២ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ដែលមានទឹកប្រាក់ចំនួន ៣,០០០$ (បីពាន់ដុល្លារអាមេរិកគត់) និងចុងចម្លើយបានផ្តល់ឱ្យអត្រាការប្រាក់ចំនួន ២៤០$ ក្នុងមួយខែ ដូចការខ្ចីប្រាក់លើកទី១ ដែរ។ ចុងចម្លើយបានបង់ការប្រាក់ទៅឱ្យដើមចោទបានរយៈពេល ៣ខែចាប់ពីខែកក្កដា ដល់ខែកញ្ញា ឆ្នាំ២០២២។ ហើយចាប់ពីខែតុលា ឆ្នាំ២០២២ រហូតមកដល់បច្ចុប្បន្ននេះ ចុងចម្លើយឈ្មោះ [redacted] ផល្លា ពុំទាន់បានសងប្រាក់ដើម និងបង់ការប្រាក់ទាំងការខ្ចីប្រាក់លើកទី១ និងលើកទី២ ទៅឱ្យដើមចោទនៅឡើយទេលុះក្រោយមក ចុងចម្លើយឈ្មោះ [redacted] ផល្លា បានមកសុំដកប្លង់ដែលខ្លួនទុកនៅដើមចោទ ដើម្បីធានាកាតព្វកិច្ចក្នុងកិច្ចសន្យានោះទៅវិញ ដោយបានប្រាប់ដើមចោទថា ខ្លួនយកប្លង់ដីនោះទៅដាក់នៅធនាគារ ដើម្បីយកប្រាក់មកសងដើមចោទ។ បន្ទាប់ពីចុងចម្លើយយកប្លង់ដីនោះទៅដាក់នៅធនាគារមក ចុងចម្លើយពុំបានយកប្រាក់មកសងដើមចោទនោះទេ។ ចំណែកឯនៅក្នុងកំណត់ហេតុស្តីពីការសម្រុះសម្រួលបឋមករណីវិវាទ រវាងឈ្មោះ [redacted] ស៊ុយ និង [redacted] ផល្លា ករណីបំពានកិច្ចសន្យាខ្ចីប្រាក់ ធ្វើឡើងនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ ២០២៣ វិញ ភាគីដើមចោទឈ្មោះ [redacted] ស៊ុយ បានយល់ព្រមឱ្យចុងចម្លើយឈ្មោះ [redacted] ផល្លា ទទួលស្គាល់ប្រាក់ដើមទាំងការខ្ចីប្រាក់លើកទី១ និងលើកទី២ ត្រឹមចំនួន ៤៥០០$ (បួនពាន់ប្រាំរយដុល្លារអាមេរិកគត់) ដោយហេតុថាដើមចោទនិងចុងចម្លើយសុទ្ធតែជាអ្នកធ្លាប់ស្គាល់គ្នាពីមុនមក ទើបដើមចោទមានការយោគយល់អាធ្យាស្រ័យដល់ចុងចម្លើយជាខ្លាំង ហើយចុងចម្លើយបានសុំដើមចោទបង់ជាការប្រាក់ក្នុង១ខែ ៥៥$ រៀងរាល់ខែនៅថ្ងៃទី៣០ ហើយប្រសិនបើដល់ថ្ងៃទី៣០ ចុងចម្លើយ មិនបង់ការប្រាក់ទៅឱ្យដើមចោទទេ នោះចុងចម្លើយនឹងបង់ប្រាក់បន្ថែមចំនួន ២០$ ពីលើការប្រាក់នោះ។ បន្ទាប់មកដើមចោទក៏បានឯកភាពតាមការស្នើសុំរបស់ចុងចម្លើយព្រោះដើមចោទចង់បញ្ចប់វិវាទត្រឹមសាលាស្រុកអង្គស្នួលនេះតែម្តង។ ប៉ុន្តែចាប់តាំងពីពេលសម្រុះសម្រួលគ្នានៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៣ មក ចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងការបង់ការប្រាក់ ១ខែ ៥៥$ តាមការស្នើសុំរបស់ខ្លួននោះទេ។ ដែលជាហេតុធ្វើឱ្យដើមចោទមិនអាចទ្រាំទ្រនឹងទង្វើទុច្ចរិតរបស់ចុងចម្លើយបាន ទើបដើមចោទសម្រេចចិត្តប្តឹងទៅសាលាដំបូងខេត្តកណ្តាល និងសូមប្រានចោលការទទួលស្គាល់ប្រាក់ដើមចំនួន ៤៥០០$ (បួនពាន់ប្រាំរយដុល្លារអាមេរិកគត់) នៅសាលាស្រុកអង្គស្នួល ដោយទាមទារប្រាក់ដើមសរុបចំនួន ៦,០០០$ (ប្រាំមួយពាន់ដុល្លារអាមេរិកគត់) វិញ និងការប្រាក់ចាប់ពីខែ ១០ ឆ្នាំ២០២២ រហូតមកដល់បច្ចុប្បន្នមានរយៈពេល ១៦ខែ ស្មើនឹងចំនួនទឹកប្រាក់ ៧,៦៨០$ (ប្រាំពីពាន់ប្រាំមួយរយប៉ែតសិបដុល្លារអាមេរិកគត់) ព្រោះមកដល់ដំណាក់កាលនៅសាលាដំបូងខេត្តកណ្តាលនេះកូនក្តីរបស់ខ្លួនលែងមានការយោគយល់អាធ្យាស្រ័យដល់ចុងចម្លើយតទៅទៀតហើយ ព្រោះចុងចម្លើយបានព្យាយាមគេចវេសមិនសងប្រាក់



Scanned with CamScanner

និងការប្រាក់ខាងលើដែលជាហេតុនាំឱ្យប៉ះពាល់ដល់ផល ប្រយោជន៍ជាសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរបំផុតដល់កូនក្ដីរបស់ខ្លួន និងមានការខាតបង់នូវពេលវេលាផ្ទាល់ខ្លួនជាច្រើនក្នុងការចំណាយពេលដោះស្រាយវិវាទពីមួយដំណាក់កាលទៅមួយដំណាក់កាល។

_យោងតាមមាត្រា ៥៩១ នៃក្រមរដ្ឋប្បវេណីស្ដីពីករណីយកិច្ចត្រូវសងប្រាក់ដើម និងបង់ការប្រាក់របស់អ្នកខ្ចី ៖ ១- អ្នកខ្ចីមានករណីយកិច្ចត្រូវសងទៅអ្នកឱ្យខ្ចី នូវវត្ថុដែលមានប្រភេទ គុណភាព និងចំនួន ស្មើគ្នានឹងវត្ថុ ដែលបានទទួលការប្រគល់ នៅថ្ងៃដែលត្រូវសង។ ២- អ្នកខ្ចីនៃកិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់ ត្រូវបង់ការប្រាក់ តាមបញ្ញត្តិពីមាត្រា ៥៨៤ (អត្រាការប្រាក់ដែលកំណត់ដោយច្បាប់ និងអត្រាការប្រាក់ក្នុងកិច្ចសន្យា) ដល់មាត្រា ៥៨៦ (ពេលវេលានៃការបង់ការប្រាក់ និងការប្រាក់សមាសដែលកំណត់ដោយច្បាប់) នៃក្រមនេះ ។

_យោងតាមមាត្រា ៣៩០ នៃក្រមរដ្ឋប្បវេណីស្ដីពីវិធីសង្គ្រោះចំពោះការមិនអនុវត្តកាតព្វកិច្ច៖ ក្នុងករណីដែល មានការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុល ម្ចាស់បំណុលអាចទាមទារឱ្យអនុវត្តដោយបង្ខំ សងសំណង នៃការខូចខាត ឬរំលាយកិច្ចសន្យា ។

_មាត្រា ៣៩៣ នៃក្រមរដ្ឋប្បវេណីស្ដីពីការអនុវត្តកាតព្វកិច្ចមិនបានពេញលេញ៖ ការមិនអនុវត្តកាតព្វកិច្ចសំដៅទៅលើករណីដែលកូនបំណុលបានអនុវត្តកាតព្វកិច្ច តែការផ្ដល់តាវកាលិកមិនពេញលេញ ឬ ករណី ដែលបានអនុវត្តតែមួយផ្នែកនៃកាតព្វកិច្ច ឬ ករណីផ្សេងទៀតដែលគ្មានការអនុវត្តឱ្យ បានពេញលេញតាម ខ្លឹមសារនៃកាតព្វកិច្ច ។

_មាត្រា ៣៩៨ នៃក្រមរដ្ឋប្បវេណីស្ដីពីល័ក្ខខណ្ឌនៃការទទួលខុសត្រូវក្នុងការសងសំណងនៃ ការខូចខាត ចំណុចទី១៖ ក្នុងករណីដែលកូនបំណុលមិនបានអនុវត្តកាតព្វកិច្ចទេម្ចាស់បំណុលអាចទាមទារ សំណងនៃ ការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ចនោះបាន។

_មាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណីស្ដីអំពីការបំពានកិច្ចសន្យាធ្ងន់ធ្ងរ ចំណុចទី១៖ "ការបំពានកិច្ចសន្យាយ៉ាង ធ្ងន់ធ្ងរសំដៅទៅលើករណីដែលភាគីម្ខាងមិនអាចសម្រេចនូវគោលបំណងនៃកិច្ចសន្យាបានដោយសារការបំពានរបស់ភាគីម្ខាងទៀត" ។

ខ្លួនជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ដោយផ្អែកតាមរយៈអង្គហេតុ និងអង្គច្បាប់ខាងលើនេះ ខ្លួនសូមធ្វើការសំណូមពរដល់លោកចៅក្រម មេត្តាសម្រេចចេញនូវសាលក្រមចំពោះការស្នើសុំ និងការ ទាមទាររបស់កូនក្ដីរបស់ខ្លួនមានដូចខាងក្រោម ៖

១. ប្រាក់ដើមចំនួន ៦០០០៛(ប្រាំមួយពាន់ដុល្លារអាមេរិកគត់)

២. ការប្រាក់ចំនួន ៧,៦៨០៛(ប្រាំពីពាន់ប្រាំមួយរយប៉ែតសិបដុល្លារអាមេរិកគត់)

៣. សំណងជម្ងឺចិត្តចំនួន ៤,៥០០៛(បួនពាន់ប្រាំរយដុល្លារអាមេរិកគត់)

៤. ថ្លៃសេវាកម្មច្បាប់(មេធាវី) ចំនួន ៣,៥០០៛(បីពាន់ប្រាំរយដុល្លារអាមេរិកគត់) ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកចៅក្រម មេត្តាពិនិត្យ និងសម្រេចតាមនីតិវិធីច្បាប់ ដោយសេចក្ដីអនុគ្រោះជាទីបំផុត ។

**១.៣.២-<u>សេចក្ដីថ្លែងការណ៍របស់ចុងចម្លើយ</u>**

*- លោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] ផល្លា បានធ្វើសេចក្ដីថ្លែងការណ៍ថា:* ពាក់ព័ន្ធទៅនឹងរឿង កូនក្ដីរបស់ខ្លួនឈ្មោះ [redacted] ផល្លា និងដើមចោទឈ្មោះ [redacted]ស៊ុយ បានដោះស្រាយ សម្រប់សម្រួលជាមួយគ្នា លើកទី១នៅសាលាស្រុកអង្គស្នួល ដែលមានកំណត់ហេតុសះជា ចុះថ្ងៃទី២១



Scanned with CamScanner

ខែមេសា ឆ្នាំ២០២៣ បានព្រមព្រៀងជាមួយគ្នា ដោយដើមចោទ និងភាគីកូនក្តីខ្លួនព្រមទទួលស្គាល់យកទឹកប្រាក់ចំនួន ៤៥០០ ដុល្លារអាមេរិក ដោយខ្លួនបានដាក់ភស្តុតាងជូនតុលាការពិនិត្យរួចមកហើយ ដូច្នេះខ្លួនជាមេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ [redacted]ផល្លា សុំប្រាណចោល គ្រប់ចំណុចដែលមេធាវីដើមចោទ បានថ្លែងការណ៍ទាមទារ ចំពោះកូនក្តីខ្លួន ព្រោះយល់ឃើញថានៅក្នុងការទាមទារ មានភស្តុតាងណាមួយ ដើម្បីបញ្ជាក់ ផ្អែកតាមការទាមទារ របស់មេធាវីដើមចោទនោះឡើយ ។ ដូច្នេះខ្លួនសុំទទួលស្គាល់ទឹកប្រាក់សរុបចំនួន ៤,៥០០ ដុល្លារអាមេរិក។ ពាក់ព័ន្ធទៅលើការថ្លែងការណ៍របស់មេធាវីដើមចោទ បានថ្លែងការណ៍ទទួលស្គាល់លើកំណត់ហេតុសះជា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៣ របស់សាលាស្រុកអង្គស្នួល បានព្រមព្រៀង ដោយទទួលស្គាល់យកទឹកប្រាក់ចំនួន ៤,៥០០ ដុល្លារអាមេរិក ក្រៅពីនេះ សុំប្រាណចោលទាំងអស់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមតុលាការសម្រេចតាមភស្តុតាងដែលខ្លួនដាក់ជូនតុលាការ និងថ្លែងការណ៍ខាងលើ។

**១.៣.៣-ចំណុចវិវាទក្នុងរឿងក្តីនេះគឺ:**

-ទាមទារប្រាក់ដើមទាំងពីរលើកចំនួន ៦,០០០ ដុល្លារអាមេរិក។

-ការប្រាក់ទាំងពីរលើកសរុបចំនួន ៧,៦៨០ ដុល្លារអាមេរិក។

-សំណងជម្ងឺចិត្ត ៤,៥០០ ដុល្លារអាមេរិក។

-សេវាកម្មច្បាប់ ៣,៥០០ ដុល្លារអាមេរិក។

## ការពិនិត្យភស្តុតាង

*+ ភស្តុតាងរបស់ភាគីដើមចោទ*

-កិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ធ្វើឡើងរវាងឈ្មោះ [redacted]ស៊ុយ និងឈ្មោះ[redacted]ផល្លា ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២។ (ថតចម្លង)

-កំណត់ហេតុស្តីពីការចុះសម្រុះសម្រួលបឋមករណីវិវាទ នៅសាលាស្រុកអង្គស្នួល រវាងឈ្មោះ[redacted]ស៊ុយ និងឈ្មោះ[redacted]ផល្លា ករណីបំពានកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣។ (ថតចម្លង)

-បញ្ជីសម្រង់វត្តមាន ពីការសម្របសម្រួលរវាងឈ្មោះ[redacted]ស៊ុយ និង [redacted]ផល្លា ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣។ (ថតចម្លង)

-កំណត់ហេតុស្តីពីការចុះសម្របសម្រួលបឋមករណីវិវាទ នៅសាលាស្រុកអង្គស្នួល រវាងឈ្មោះ [redacted] ស៊ុយ និង[redacted]ផល្លា ករណីបំពានកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៣។ (ថតចម្លង)

-បញ្ជីសម្រង់វត្តមាន ស្តីពីការសម្របសម្រួលរវាងឈ្មោះ [redacted]ស៊ុយ និង [redacted]ផល្លា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៣។ (ថតចម្លង)

*+ ភស្តុតាងជាឯកសាររបស់ភាគីចុងចម្លើយ*

-កំណត់ហេតុស្តីពីការសម្រុះសម្រួលបឋមករណីវិវាទរវាងឈ្មោះ [redacted] ស៊ុយ និង [redacted] ផល្លា ករណីបំពានកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៣ របស់សាលាស្រុកអង្គស្នួលចំនួន ០១ច្បាប់ ០២សន្លឹក។ (ថតចម្លង)

## ២.សំអាងហេតុ

**២.១**-គូភាគីពិតជាបាន ចុះកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ ដោយមានការព្រមព្រៀងគ្នា គ្មានការបង្ខិតបង្ខំឡើយ ហើយគឺជាកិច្ចសន្យាអញ្ញមញ្ញ ហើយបានបញ្ជាក់ថា សហចុងចម្លើយពិតជាបានជំពាក់ប្រាក់ដើមចោទចំនួន០២លើក លើកទី១ចំនួន **៣,០០០ ដុល្លារអាមេរិក** សរសេរជាអក្សរ **(បីពាន់ដុល្លារអាមេរិកគត់)** និងលើកទី២ ចំនួន **៣,០០០ ដុល្លារអាមេរិក** សរសេរជាអក្សរ **(បីពាន់ដុល្លារអាមេរិកគត់)** ពិតប្រាកដមែន ។ ហេតុនេះគប្បីតុលាការសម្រេចកំណត់ឱ្យចុងចម្លើយសងប្រាក់ដើមចំនួន **៦,០០០ ដុល្លារអាមេរិក** សរសេរជាអក្សរ **(ប្រាំមួយពាន់ដុល្លារអាមេរិកគត់)** ទៅឱ្យដើមចោទតាមការទាមទារ ។



Scanned with CamScanner

**២.២**-តាមការអះអាងរបស់មេធាវីតំណាងដោយអណត្តិឱ្យដើមចោទថា តាមរយៈអង្គហេតុនៃកម្ចីប្រាក់លើកទី១ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ រវាងដើមចោទឈ្មោះ [redacted] ស៊ុយ និងចុងចម្លើយឈ្មោះ [redacted] ផល្លា បានព្រមព្រៀងគ្នា បង្កើតកិច្ចសន្យាខ្ចីបរិភោគចំនួន ៣,០០០ ដុល្លារអាមេរិក ដោយភ្ជាប់ការប្រាក់ចំនួន ២៤០ ដុល្លារអាមេរិក ក្នុងមួយខែ និងលើកទី២ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ប្រាក់ចំនួន ៣,០០០ ដុល្លារអាមេរិក ដោយភ្ជាប់ការប្រាក់ ២៤០ ដុល្លារអាមេរិក ក្នុងមួយខែ។ តែចំពោះអត្រាការប្រាក់កម្ចីលើកទី១ ចុងចម្លើយបានបង់ អត្រាការប្រាក់ពីខែកុម្ភៈ ដល់ខែកញ្ញាបានចំនួន ១,០០០ ដុល្លារអាមេរិក ដោយឡែកចំពោះកម្ចីលើកទី២ ចុងចម្លើយបានបង់ការប្រាក់ចំនួន ១៥៥ ដុល្លារអាមេរិក សម្រាប់រយៈពេល៣ខែ ពីខែកក្កដា ដល់ខែកញ្ញា ហើយចាប់ពីខែតុលា ឆ្នាំ២០២២ មកដល់បច្ចុប្បន្ន ចុងចម្លើយមិនបានបង់ការប្រាក់នោះទេ។ ដែលសរុបការប្រាក់ទាំងការខ្ចីលើកទី១ និងទី២ នៃការប្រាក់ទាំងពីរលើក គឺមាន ៧,៦៨០ ដុល្លារអាមេរិក។

**២.៣**-តាមការអះអាងរបស់មេធាវីតំណាងដោយអណត្តិឱ្យចុងចម្លើយថា កូនក្តីរបស់ខ្លួនឈ្មោះ [redacted] ផល្លា និងដើមចោទឈ្មោះ [redacted] ស៊ុយ បានដោះស្រាយ សម្របសម្រួលជាមួយគ្នា លើកទី១នៅសាលាស្រុកអង្គស្នួល ដែលមានកំណត់ហេតុសះជា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៣ បានព្រមព្រៀងជាមួយគ្នា ដោយដើមចោទ និងភាគីកូនក្តីខ្លួន ព្រមទទួលស្គាល់យកទឹកប្រាក់ចំនួន ៤៥០០ ដុល្លារអាមេរិក ដោយខ្លួនបានដាក់ភស្តុតាងជូនតុលាការពិនិត្យរួចមកហើយ ដូច្នេះខ្លួនជាមេធាវីតំណាងដោយអណត្តិឱ្យឈ្មោះ [redacted] ផល្លា សុំប្រានចោល គ្រប់ចំណុចដែលមេធាវីដើមចោទ បានថ្លែងការណ៍ ទាមទារ ចំពោះកូនក្តីខ្លួន ព្រោះយល់ឃើញថានៅក្នុងការទាមទារមានភស្តុតាងណាមួយ ដើម្បីបញ្ជាក់ ផ្អែកតាមការទាមទារ របស់មេធាវីដើមចោទនោះឡើយ ។ ដូច្នេះខ្លួនសុំទទួលស្គាល់ទឹកប្រាក់សរុបចំនួន ៤,៥០០ ដុល្លារអាមេរិក។

**២.៤**-តាមកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ រវាងដើមចោទ និងចុងចម្លើយ គឺបានព្រមព្រៀងគ្នាខ្ចីចងការប្រាក់នូវប្រាក់ដើមចំនួន **៣,០០០$ (បីពាន់ដុល្លារអាមេរិក)** និងផ្តល់ឱ្យអត្រាការប្រាក់ចំនួន ២៤០$ ក្នុងមួយខែ ហើយចុងចម្លើយបានបង់ការប្រាក់ឱ្យដើមចោទបានរយៈពេល ៨ខែ ចាប់ពីខែកុម្ភៈ ដល់ខែកញ្ញា ឆ្នាំ២០២២។ និងលើកទី២ បានខ្ចីប្រាក់បន្ថែមនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ដែលមានទឹកប្រាក់ចំនួន **៣,០០០$ (បីពាន់ដុល្លារអាមេរិក)** បានផ្តល់អត្រាការប្រាក់ចំនួន ២៤០$ ក្នុងមួយខែ ដូចការខ្ចីប្រាក់លើកទី១ដែរ ប៉ុន្តែចុងចម្លើយបានសងការប្រាក់ទៅដើមចោទ បានចំនួនតែ **០៣ខែ** តែប៉ុណ្ណោះ ប៉ុន្តែចុងចម្លើយពុំបានបំពេញកាតព្វកិច្ច នឹងបានរំលោភទៅលើលក្ខខណ្ឌនៃកិច្ចព្រមព្រៀង ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ ២០២២ ។

**២.៥**-ចំពោះការអះអាងរបស់គូភាគីឃើញថា ពិតជាទទួលស្គាល់ពីការខ្ចីប្រាក់បរិភោគពិតមែននូវប្រាក់ដើមសរុបចំនួន ៦០០០ $ (ដុល្លារអាមេរិក) ប៉ុន្តែនៅមានការសម្របសម្រួលគ្នានៅសាលាស្រុក គឺមានការឯកភាពគ្នានៅទឹកប្រាក់ដែលត្រូវសងចំនួន ៤៥០០ $ (បួនពាន់ប្រាំរយដុល្លារ) មែន តែសុំឱ្យភាគីចុងចម្លើយសងតាមកិច្ចព្រមព្រៀងនៅសាលាស្រុកដូចមានការបញ្ជាក់ជូនខាងលើ។ ក្រោយពីបានព្រមព្រៀងគ្នារួច ភាគីចុងចម្លើយឈ្មោះ [redacted] ផល្លា មិនបានអនុវត្តកាតព្វកិច្ចឡើយ ទើបភាគីដើមចោទដាក់ពាក្យបណ្តឹងមកតុលាការ ដើមចោទមិនសុខចិត្តក្នុងការមិនគោរពកាតព្វកិច្ច និងសុំឱ្យសងប្រាក់ដើមគ្រប់ចំនួនគឺចំនួន ៦០០០ $ (ប្រាំមួយពាន់ដុល្លារ)។ ដូច្នោះ តុលាការយល់ឃើញថា ការប្តឹងទាមទាររបស់ដើមចោទ គឺពិតជាមានអត្ថិភាពនៃសិទ្ធិ គប្បីតុលាការទទួលស្គាល់ការទាមទារនៅប្រាក់ដើមរបស់ដើមចោទ។

**២.៦**-រាល់សំអាងហេតុដូចបានរៀងរាប់ខាងលើ ពិតជាមានអត្ថិភាពនៃអង្គហេតុដែលជាមូលដ្ឋាននៃការទាមទាររបស់ដើមចោទ ដែលគប្បីតុលាការសម្រេចទទួលស្គាល់ការទាមទាររបស់ដើមចោទ ។

**២.៧**-តាមមាត្រា**៦៤** កថាខណ្ឌទី**១** នៃក្រមនីតិវិធីរដ្ឋប្បវេណីប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

## ៣.<u>សេចក្តីសម្រេចបញ្ចប់</u>

**ទទួលស្គាល់ការទាមទាររបស់ដើមចោទដោយ៖**

**៣.១**-ឲ្យចុងចម្លើយឈ្មោះ [redacted] **ផល្លា** សងប្រាក់ទៅអោយដើមចោទឈ្មោះ [redacted] **ស៊ុយ** ដូចខាងក្រោម៖

**ក**/-ប្រាក់ដើមចំនួន **៦,០០០ (ប្រាំមួយពាន់ដុល្លារអាមេរិក)**



Scanned with CamScanner

ខ/-ការប្រាក់ចំនួន **១៨% (ដប់ប្រាំបីភាគរយ)** ក្នុង **០១ (មួយ) ឆ្នាំ** លើប្រាក់ដើមចំនួន **៦,០០០ (ប្រាំមួយពាន់ដុល្លារអាមេរិក)** គិតចាប់ពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន ។

**គ**-ច្រានចោលប្រាក់សំណងជម្ងឺចិត្ត សេវាកម្មផ្លូវច្បាប់។

**៣.៣**-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ ។

សាលក្រមនេះបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈនៅថ្ងៃច័ន្ទ ២រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧ ត្រូវនឹងថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៤ និងប្រកាសជាសាធារណៈ នៅថ្ងៃអង្គារ ១០កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧ ត្រូវនឹងថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ ។ ចំពោះមុខដើមចោទ និងចុងចម្លើយ ។

បើកសិទ្ធិឱ្យប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ចៅក្រម**

ហត្ថលេខា និងត្រា : [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ១០កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

កណ្ដាល, ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤

**បានឃើញ**
**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]